ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច

លេខ: ០១៨/២៥ ន.ប.ធ./ស.ជ.ណ.

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សម្រាប់ចូលបម្រើការងារនៅនិយ័តករបរធនបាលកិច្ច

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដែលជាស្ថាប័នឯករាជ្យក្នុងការបំពេញតួនាទីគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមជូនដំណឹងដល់និស្សិត និងសាធារណជនទូទៅឱ្យបានជ្រាបថា **ន.ប.ធ.** នឹងរៀបចំការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.** ចំនួន ៧ រូប ដែលមានសញ្ញាបត្រត្រូវនឹងជំនាញដែលជ្រើសរើស ស្របតាមលក្ខខណ្ឌកំណត់ ដូចខាងក្រោម៖

### ១.លក្ខខណ្ឌនៃការជ្រើសរើស

#### ក.លក្ខខណ្ឌទូទៅ

- មានសញ្ជាតិខ្មែរ និងមានអាយុច្រើនបំផុត ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅលើជំនាញនីមួយៗ
- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ
- មិនធ្លាប់មានទោសពីបទមជ្ឈិម និងបទឧក្រិដ្ឋណាមួយ
- មានចំណេះដឹងភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការបាន
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ (មួយ) ឆ្នាំ
- មានធន្ទៈខ្ពស់ ស្មោះត្រង់ ការទទួលខុសត្រូវក្នុងការងារ មានស្មារតីធ្វើការជាក្រុម
- ត្រូវមានសុខភាពល្អ និងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារ។

#### ខ.លក្ខខណ្ឌជាក់លាក់

➢ **ជំនាញនីតិសាស្ត្រ**

ចំពោះបេក្ខជន បេក្ខនារីដែលមានបំណងបម្រើការងារជំនាញនីតិសាស្ត្រ ត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវជាអប្បបរមា ដូចខាងក្រោម៖

-មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញនីតិសាស្ត្រ ជំនាញច្បាប់ ជំនាញវិទ្យាសាស្ត្រនយោបាយ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល

-មានចំណេះដឹងជាមូលដ្ឋានអំពីនីតិព្រហ្មទណ្ឌទូទៅ និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

-មានចំណេះដឹងជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ រៀបចំចងក្រង និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលផ្សេងៗ

-មានគំនិតផ្តួចផ្តើម និងភាពវាងវៃក្នុងការវិភាគ និងដោះស្រាយវិវាទ ដោយផ្សារភ្ជាប់នឹងក្របខណ្ឌបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

-រៀបចំ និងស្នើឡើងនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងយន្តការនៃការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងក្នុងវិស័យបរធនបាលកិច្ច

-រៀបចំ និងស្នើឡើងនូវលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងទម្រង់លិខិតស្នាមផ្សេងៗពាក់ព័ន្ធនឹងការធ្វើអធិការកិច្ច និងការអនុវត្តច្បាប់

-ប្រមូល និងរក្សាទុកនូវភស្តុតាង ទិន្នន័យ និងការចាត់វិធានការពិន័យផ្សេងៗ ពាក់ព័ន្ធនឹងករណីប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

## ➢ ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ចំពោះបេក្ខជន បេក្ខនារីដែលមានបំណងបម្រើការងារជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

-មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញសេដ្ឋកិច្ច ជំនាញគណនេយ្យនិងហិរញ្ញវត្ថុ ជំនាញធនាគារនិងហិរញ្ញវត្ថុ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល

-មានចំណេះដឹងស្រាវជ្រាវ ចងក្រងនិងវិភាគទិន្នន័យ

-មានចំណេះដឹងផ្នែកបច្ចេកវិទ្យាឌីជីថល ឬគោលនយោបាយឌីជីថល

-រៀបចំធ្វើបច្ចុប្បន្នភាព ស្នើឡើងនូវបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាត និង/ឬការចុះបញ្ជីនូវការបង្កើតបរធនបាលកិច្ច

-រៀបចំធ្វើបច្ចុប្បន្នភាព ស្នើឡើងនូវបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់អាជ្ញាបណ្ណការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករបរធនបាលនិងអ្នកចូលរួមដទៃទៀត

-ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍អាជីវកម្ម ប្រតិវេទន៍ និងឯកសារចាំបាច់របស់បរធនបាលកិច្ច។

## ➢ ជំនាញទំនាក់ទំនងអន្តរជាតិ

ចំពោះបេក្ខជន បេក្ខនារីដែលមានបំណងបម្រើការងារជំនាញទំនាក់ទំនងអន្តរជាតិ ត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវជាអប្បបរមា ដូចខាងក្រោម៖

-មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញទំនាក់ទំនងអន្តរជាតិ ជំនាញទំនាក់ទំនង-សាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល

-មានចំណេះដឹងផ្នែកបច្ចេកវិទ្យាឌីជីថល ឬគោលនយោបាយឌីជីថល

-រៀបចំ និងអនុវត្តផែនការសហប្រតិបត្តិការជាមួយអាជ្ញាធរ ឬស្ថាប័នគ្រប់គ្រងវិស័យបរធន-បាលកិច្ចនៃបណ្តាប្រទេសផ្សេងទៀត និងដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ

-សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយនិយ័តកររបស់វិស័យបរធនបាលកិច្ចនៃបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក

-តាមដាន និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ និងដំណើរការវិវត្តន៍ជាអន្តរជាតិក្នុងវិស័យបរធនបាលកិច្ច។

- **ជំនាញស្រាវជ្រាវ**

ចំពោះបេក្ខជន បេក្ខនារីដែលមានបំណងបម្រើការងារជំនាញស្រាវជ្រាវ ត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវជាអប្បបរមា ដូចខាងក្រោម៖

-មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញស្រាវជ្រាវ ជំនាញសេដ្ឋកិច្ចអនុវត្តន៍ ជំនាញស្ថិតិ ជំនាញសេដ្ឋកិច្ចមាត្រវិទ្យា ជំនាញទំនាក់ទំនងអន្តរជាតិ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល

-មានចំណេះដឹងផ្នែកបច្ចេកវិទ្យាឌីជីថល ឬគោលនយោបាយឌីជីថល

-សិក្សាពីយុទ្ធសាស្ត្រនានា និងរៀបចំគម្រោងផែនការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា

-សិក្សាវាយតម្លៃ និងផ្តល់យោបល់លើនវានុវត្តន៍បរធនបាលកិច្ច ព្រមទាំងផ្តល់យោបល់អំពីផលប៉ះពាល់ និងអត្ថប្រយោជន៍សម្រាប់អ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច

-ចូលរួមអនុវត្តការធ្វើសុខុមនីយកម្មនៃក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិនៅក្នុងតំបន់

-រៀបចំវចនាក្រមសម្រាប់វិស័យបរធនបាលកិច្ច។

## ២.ឯកសារភ្ជាប់

- ពាក្យសុំចុះឈ្មោះប្រឡងចូលជាមន្ត្រីលក្ខន្តិកៈ
- ជីវប្រវត្តិសង្ខេប
- សលាកបត្រឯកត្តជន
- សញ្ញាបត្រថតចម្លង (បញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច)
- អត្តសញ្ញាណបណ្ណ ឬច្បាប់ចម្លងសំបុត្រកំណើត ឬសៀវភៅគ្រួសារ (បញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមាន-សមត្ថកិច្ច)
- លិខិតថ្កោលទោសដែលមានសុពលភាព (ក្រោយជាប់ជាស្ថាពរ)
- ឯកសារបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន)
- ឯកសារបញ្ជាក់ពីកម្រិតចំណេះដឹងផ្សេងៗ (បើមាន)។

## ៣.ការជ្រើសរើស

ការជ្រើសរើសត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងលើវិញ្ញាសាសរសេរ និងការធ្វើសំភាសន៍ផ្ទាល់មាត់ពីអនុគណៈកម្មការរៀបចំការសម្ភាសន៍។ បេក្ខជនដែលប្រឡងជាប់លើវិញ្ញាសាសរសេរត្រូវឆ្លងកាត់ការសម្ភាសន៍ផ្ទាល់មាត់ដើម្បីសម្រេចលទ្ធផលស្ថាពរ។

**បញ្ជាក់៖** មានតែបេក្ខជន បេក្ខនារី ដែលត្រូវបានជាប់ដំណាក់កាលសម្រាំង (shortlisted Candidates) ប៉ុណ្ណោះ ដែលអាចចូលរួមធ្វើតេស្តលើវិញ្ញាសាសរសេរបាន ហើយមានតែបេក្ខជន បេក្ខនារី ដែលប្រឡងជាប់លើវិញ្ញាសាសរសេរប៉ុណ្ណោះ ទើបអាចចូលរួមធ្វើតេស្តសមត្ថភាពលើការសម្ភាសន៍ផ្ទាល់មាត់បាន។

## ៤.ការដាក់ពាក្យស្នើសុំជ្រើសរើស

បេក្ខជន បេក្ខនារី អាចទាញយកពាក្យសុំចូលរួមប្រឡងតាមរយៈតំណភ្ជាប់ QR code ខាងក្រោម រួចធ្វើការបំពេញ និងត្រូវមកដាក់ពាក្យស្នើសុំសិទ្ធិប្រឡងនៅទីស្តីការ **ន.ប.ធ.** ដែលមានអាសយដ្ឋានអគារ ១៦៨F (ជាន់ទី៨) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ***ចាប់ពីការផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង ៤:០០ នាទីរសៀល។***

ចំពោះកាលបរិច្ឆេទប្រឡង និងបញ្ជីរាយនាមបេក្ខជន បេក្ខនារី នឹងត្រូវផ្សព្វផ្សាយនៅលើគេហទំព័រ www.trustregulator.gov.kh, Facebook Page និង Telegram channel របស់ **ន.ប.ធ.**។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរសព្ទ ០៧៨ ៨៧ ៨៧ ៦៥ (Telegram)។

**និយ័តករបរធនបាលកិច្ច**

**សម្គាល់៖** បេក្ខជន បេក្ខនារី អាចទាញយកពាក្យសុំចូលរួមប្រឡងបាន តាមរយៈ QR Code ខាងក្រោម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំចុះឈ្មោះប្រឡងប្រជែងចូលបម្រើការងារ ជាមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សម្រាប់ចូលបម្រើការងារនៅនិយ័តករបរធនបាលកិច្ច

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..............................ជាអក្សរឡាតាំង..............................ភេទ................ សញ្ជាតិ..............កើតថ្ងៃទី.........ខែ............ឆ្នាំ............នៅភូមិ......................ឃុំ/សង្កាត់.................... ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត..............................។

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយក នៃនិយ័តករបរធនបាលកិច្ច**

ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមអគ្គនាយក** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ខ្ញុំបាទ/នាងខ្ញុំ មានបំណងចូលបម្រើការងារជាមន្ត្រីលក្ខន្តិកៈ ជំនាញ៖...................................នៅនិយ័តករបរធនបាលកិច្ច នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

អាស្រ័យហេតុនេះសូម **ឯកឧត្តមអគ្គនាយក** មេត្តាពិនិត្យលទ្ធភាពចុះឈ្មោះ ខ្ញុំបាទ/នាងខ្ញុំ ក្នុងបញ្ជីបេក្ខជន/បេក្ខនារី ប្រឡងប្រជែងចូលបម្រើការងារជាមន្ត្រីលក្ខន្តិកៈនៅនិយ័តករបរធនបាលកិច្ច នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយក្តីអនុគ្រោះ។

សូមគោរពភ្ជាប់មកជាមួយនូវ៖

១.ប្រវត្តិរូបសង្ខេប (មានបិទរូបថត ៤ x៦) ចំនួន ០១ច្បាប់

២.ច្បាប់ចម្លងសញ្ញាបត្រដោយមានបញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច ចំនួន ០១ច្បាប់

៣.សលាកបត្រឯកត្តជន ចំនួន ០១ច្បាប់

សូម **ឯកឧត្តមអគ្គនាយក** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ........................ខែ.............ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ២០២...

**ហត្ថលេខា និងឈ្មោះសាមីខ្លួន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត
៤X៦

# ប្រវត្តិរូបសង្ខេប

## ក.ព័ត៌មានផ្ទាល់ខ្លួន

គោត្តនាមនិងនាមខ្លួន....................................អក្សរពុម្ពឡាតាំង...................................ភេទ...................

សញ្ជាតិ.........ជនជាតិ..........ថ្ងៃខែឆ្នាំកំណើត...............................ទីកន្លែងកំណើត ភូមិ...........................

ឃុំ/សង្កាត់........................ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត..........................................។

អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ.................ផ្លូវ.............ភូមិ...........................ឃុំ/សង្កាត់............................
ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត................................។

អ៊ីម៉ែល.....................................លេខទូរសព្ទ..........................អត្តសញ្ញាណប័ណ្ណ..............................។

## ខ.ព័ត៌មានអំពីគ្រួសារ

ឈ្មោះប្តី/ប្រពន្ធ......................................អក្សរពុម្ពឡាតាំង...............................ស្ថានភាព.......................

ថ្ងៃខែឆ្នាំកំណើត........................................មុខរបរ............................អង្គភាព.......................................

ចំនួនកូន.................នាក់។

## គ.កម្រិតវប្បធម៌ទូទៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលបន្ត

| វគ្គ ឬកម្រិតសិក្សា | គ្រឹះស្ថានបណ្តុះបណ្តាល និងទីកន្លែង | សញ្ញាបត្រដែលទទួលបាន | ថ្ងៃខែឆ្នាំសិក្សា | |
|---|---|---|---|---|
| | | | ចូល | បញ្ចប់ |
| កម្រិតវប្បធម៌ទូទៅ | | | | |
| | | | ..../..../.... | ..../..../.... |
| | | | ..../..../.... | ..../..../.... |
| | | | | |

| កម្រិតសញ្ញាបត្រ | | | | |
|---|---|---|---|---|
| | | | .../.../.... | .../.../.... |
| | | | .../.../.... | .../.../.... |
| | | | | |
| **ជំនាញឯកទេស** | | | | |
| | | | .../.../.... | .../.../.... |
| | | | .../.../.... | .../.../.... |
| | | | .../.../.... | .../.../.... |

## ឃ.បទពិសោធន៍ការងារ

| ថ្ងៃខែឆ្នាំបំពេញការងារ | | អង្គភាព | មុខតំណែង | ផ្សេងៗ |
|---|---|---|---|---|
| ចូល | បញ្ចប់ | | | |
| .../.../.... | .../.../.... | | | |
| .../.../.... | .../.../.... | | | |
| .../.../.... | .../.../.... | | | |

## ង.សមត្ថភាពភាសាបរទេស

| ល.រ | ភាសា | អាន | សរសេរ | និយាយ | ស្តាប់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាអះអាង និងទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានដែលបានបំពេញខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន។

***សូមភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធ**

ថ្ងៃ.........................ខែ.............ឆ្នាំ.................... ព.ស. ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២......

**ហត្ថលេខា និងឈ្មោះសាមីខ្លួន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបេតធនបាលកិច្ច**

## សលាកបត្រឯកត្តជន

រូបថត
៤ x៦

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...........................................អក្សរពុម្ពឡាតាំង...........................................

ភេទ...........សញ្ជាតិ.........កើតថ្ងៃទី..........ខែ.............ឆ្នាំ.............នៅភូមិ...............................

ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត...........................................

អាសយដ្ឋានបច្ចុប្បន្ន៖ .......................................................................................................

លេខទូរសព្ទទំនាក់ទំនង៖.......................................................................................................

ថ្ងៃ....................ខែ............ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦... ថ្ងៃ.................ខែ... ....ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ២០២..... រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ២០២.....

អ្នកទទួលពាក្យ ហត្ថលេខា និងឈ្មោះសាមីខ្លួន

**កំណត់សម្គាល់៖** បេក្ខជនត្រូវបង្ហាញសលាកបត្រឯកត្តជនដល់អនុរក្សនៅពេលចូលប្រឡង។

-----✂-----------------------------------------------------------------------------------------

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបេតធនបាលកិច្ច**

សលាកបត្រឯកត្តជន

រូបថត
៤ x៦

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...........................................អក្សរពុម្ពឡាតាំង...........................................

ភេទ...........សញ្ជាតិ.........កើតថ្ងៃទី..........ខែ.............ឆ្នាំ.............នៅភូមិ...............................

ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត...........................................

អាសយដ្ឋានបច្ចុប្បន្ន៖ .......................................................................................................

លេខទូរសព្ទទំនាក់ទំនង៖.......................................................................................................

ថ្ងៃ................ខែ...........ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦... ថ្ងៃ.....................ខែ............ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ២០២..... រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ២០២.....

អ្នកទទួលពាក្យ ហត្ថលេខា និងឈ្មោះសាមីខ្លួន

**កំណត់សម្គាល់៖** បេក្ខជនត្រូវបង្ហាញសលាកបត្រឯកត្តជនដល់អនុរក្សនៅពេលចូលប្រឡង។